**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

**អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ**

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**

លេខ:១០៦.......អ.ស.អ.....

ប្រព័ន្ធ scan 24/4/12

**សូមគោរពជូន**

**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ៖** របាយការណ៍ស្តីពី " លទ្ធផលនៃការអនុវត្តការងាររបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិប្រចាំត្រីមាសទី ១ ឆ្នាំ ២០១២

**យោង** ៖ លិខិតលេខ១៨៩៨ ពណរប ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ ២០១២ របស់ក្រសួងពាណិជ្ជកម្ម

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមគោរព និងរាយការណ៍ជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តការងាររបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិប្រចាំត្រីមាសទី ១ ឆ្នាំ ២០១២ មានដូចខាងក្រោម:

I- **អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម** (Trade SWAp)

**១.១) កិច្ចប្រជុំអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងវិស័យពាណិជ្ជកម្ម**

បានរៀបចំកិច្ចប្រជុំ SSC-TD&TRI លើកទី៩ ថ្ងៃទី១៧ខែកុម្ភៈឆ្នាំ២០១២ ក្នុងដំណើរការពិនិត្យ ការអនុវត្ត និងប្រសិទ្ធភាពរបស់គម្រោងTDSP និងគម្រោង EIF Tier 1។ ជាលទ្ធផល **ឯកឧត្តមទេស រដ្ឋមន្ត្រី** ក្នុងនាមជាប្រធានអនុគណៈកម្មការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទង និងពាណិជ្ជកម្ម ( SSC -TD -TRI )បានផ្តល់អនុសាសន៍និងណែនាំដូចខាងក្រោម៖

- អបអរសាទរចំពោះលទ្ធផលនៃការវាយតម្លៃរបស់ធនាគារពិភពលោក និងក្រុមវាយតម្លៃឯករាជ ECORYS ដែលបានទទួលស្គាល់លទ្ធផលការអនុវត្តគម្រោងឆ្នាំ ២០១១ ទទួលបានកម្រិត Satisfactory ឆ្នាំ ២០១១
- អនុម័តផែនទីបង្ហាញផ្លូវ(Roadmap) របស់ក្រុមសសរស្តម្ភទាំងបី នៃអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម(Trade SWAp)
- ឯកភាពលើនិតិវិធីថ្មីចំពោះការដាក់វាយតម្លៃ និងអនុវត្តគម្រោង( Project Approval Process under TDSP ក្រោមកម្មវិធី TDSP ។



1792
Apr 23/12